# ប្រកាស

# ស្តីពី

## ការផ្ទេរប្រតិភូកម្មអំណាចដល់អភិបាលខេត្ត

## ក្រុង

## ក្នុងការជួយគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់

**រាជរដ្ឋាភិបាលកម្ពុជា**

**ក្រសួងមហាផ្ទៃ**

លេខ : ១៨៨៤ប្រ.ក

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ប្រកាស

## ស្តីពី

## ការធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត ក្រុង ក្នុងការជួយគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់

## សហរដ្ឋមន្ត្រី

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មិនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៥០១/១៧៥ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់

-បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ

-បានឃើញអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ មិនា ឆ្នាំ ២០០២ ស្តីពីការធ្វើវិមជ្ឈការអំណាចតួនាទី និងភារកិច្ច ទៅអោយក្រុមប្រឹក្សាឃុំ សង្កាត់

-យោងតាមសេចក្តីសំរេចនៃអង្គប្រជុំរបស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ កាលពីថ្ងៃទី ១៤ ខែ មិនា ឆ្នាំ ២០០២

## សំរេច

## ជំពូកទី ១

## អំពីបទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ត្រូវបានធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត ក្រុង ក្នុងនាមរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីសម្របសម្រួលការអនុវត្តន៍ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងការអនុវត្តន៍គោលនយោបាយវិមជ្ឈការ នៅតាមខេត្ត ក្រុងនីមួយៗ ផ្អែកតាមការសម្រេចរបស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ (គ.ឃ.ស) ។

បទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះចែងអំពីតួនាទី និងការទទួលខុសត្រូវចំបងៗរបស់អភិបាលខេត្ត ក្រុង ក្រោមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងគោលនយោបាយវិមជ្ឈការ ។

**ប្រការ ២.-**

អភិបាលខេត្ត ក្រុងត្រូវជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យមានសមត្ថភាពដើម្បីអនុវត្តអំណាច និងមុខងារស្របទៅតាម :

-ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

-ព្រះរាជក្រឹត្យ និង

-អនុក្រឹត្យ ប្រកាស ឬលិខិតបទដ្ឋាននានាដែលមានជាធរមាន ។

**ប្រការ ៣.-**

អភិបាលខេត្ត ក្រុងត្រូវជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការបន្តអនុវត្តកិច្ចព្រមព្រៀង ឬការចាត់ចែងបន្តនូវការងារដែលបានធ្វើឡើងក្នុងនាមឃុំ សង្កាត់មុនពេលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងករណីដែលកិច្ចព្រមព្រៀង ឬការងារទាំងនោះមានលក្ខណៈសមស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋាននានាដែលមានជាធរមាន ។

ចំពោះកិច្ចព្រមព្រៀង ឬការងារនានាដែលបានធ្វើឡើងក្នុងនាមឃុំ សង្កាត់ មុនពេលបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ក៏អាចបន្តអនុវត្តបាន ប្រសិនបើក្រុមប្រឹក្សាឃុំ សង្កាត់យល់ឃើញថា កិច្ចព្រមព្រៀង ឬការងារទាំងនោះមិនផ្ទុយនឹងគោលការណ៍ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងគោលនយោបាយវិមជ្ឈការ ប៉ុន្តែត្រូវជូនពត៌មានដល់អភិបាលខេត្ត ក្រុង ។

ចំពោះកិច្ចព្រមព្រៀង ឬការងារណាមួយដែលនៅស្រពិចស្រពិល ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវពិគ្រោះយោបល់ជាមួយអភិបាលខេត្ត ក្រុង តាមរយៈអភិបាលស្រុក ខ័ណ្ឌមុននឹងបន្តអនុវត្ត ។

## ជំពូកទី ២

## អំពីអង្គភាពរដ្ឋបាលមូលដ្ឋាន

### ប្រការ ៤.-

ត្រូវបង្កើតអោយមានអង្គភាពរដ្ឋបាលមូលដ្ឋានចំណុះសាលាខេត្ត ក្រុង និងសាលាស្រុក ខ័ណ្ឌ ដើម្បីធ្វើជាសេនាធិការជូនអភិបាលខេត្ត ក្រុង ស្រុក ខ័ណ្ឌ ក្នុងការអនុវត្តគោលនយោបាយវិមជ្ឈការ ។

ការរៀបចំ និង ការប្រព្រឹត្តទៅនៃអង្គភាពរដ្ឋបាលមូលដ្ឋានត្រូវកំណត់ដោយប្រកាសដោយឡែករបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមការសម្រេចរបស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

### ប្រការ ៥.-

អភិបាលខេត្ត ក្រុង គឺជាច្រកផ្លូវការនៃទំនាក់ទំនងរវាងក្រុមប្រឹក្សាឃុំ សង្កាត់ នៅក្នុងខេត្ត ក្រុងរបស់ខ្លួន ជាមួយរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន ឬភ្នាក់ងាររបស់រាជរដ្ឋាភិបាល ព្រមទាំងអង្គការជាតិ និងអន្តរជាតិនានា ។

## ជំពូកទី ២

## អំពីការកសាងសមត្ថភាព

### ប្រការ ៦.-

អភិបាលខេត្ត ក្រុងត្រូវវាយតំលៃហើយធានាថា :

-អង្គភាពរដ្ឋបាលមូលដ្ឋានក្នុងខេត្ត ក្រុងរបស់ខ្លួនមានធនធានមនុស្ស និងធនធានសំភារៈ សមស្របក្នុងការអនុវត្តគោលនយោបាយវិមជ្ឈការ ។

-មន្ត្រីដែលបំរើការងារក្នុងអង្គភាពនេះ មានសមត្ថភាពគ្រប់គ្រាន់ និងអនុវត្តបានត្រឹមត្រូវតាមតួនាទី និងការទទួលខុសត្រូវក្នុងការអនុវត្តន៍ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងលិខិតបទដ្ឋាននានាសំរាប់អនុវត្តច្បាប់នេះ ។

ក្នុងករណីដែលមិនអាចធានាបាននូវបញ្ហាខាងលើនេះ អភិបាលខេត្ត ក្រុងត្រូវអន្តរាគមន៍មកក្រសួងមហាផ្ទៃក្នុងការផ្តល់នូវធនធានមនុស្ស និងធនធានសំភារៈ អោយបានសមស្រប និងទាន់ពេលវេលា ព្រមទាំងការបណ្តុះបណ្តាលសមត្ថភាព ដើម្បីបង្កលក្ខណៈអោយមន្ត្រីទាំងនោះទទួលបាននូវការយល់ដឹងសមស្របពីមុខជំនាញដែលពាក់ព័ន្ធ និងមានឥរិយាបថការងារឱ្យបានត្រឹមត្រូវ ។

### ប្រការ ៧.-

អភិបាលខេត្ត ក្រុងត្រូវត្រួតពិនិត្យ និងវាយតំលៃ :

-អំពីការអនុវត្តន៍នូវតួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ និងមន្ត្រីដែលបានតែងតាំងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីរៀបចំការកសាងសមត្ថភាពឱ្យបានសមស្រប

-អំពីតំរូវការខាងធនធានមនុស្ស និងធនធានសំភារៈសមស្រប សម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់

-អំពីការយល់ដឹងជំនាញ និងឥរិយាបថការងាររបស់មន្ត្រីដែលបានតែងតាំង និងដែលបានបោះឆ្នោតជ្រើសរើសឡើងដោយប្រជាពលរដ្ឋ ក្នុងការអនុវត្តតួនាទី និងការទទួលខុសត្រូវក្រោមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងលិខិតបទដ្ឋាននានាសំរាប់អនុវត្តច្បាប់នេះ ។

**ប្រការ ៨.-**

អភិបាលខេត្ត ក្រុងត្រូវពិនិត្យ និងវាយតំលៃ អំពីការកំណត់តួនាទី និងការទទួលខុសត្រូវរបស់មន្ត្រីនៃក្រសួងពាក់ព័ន្ធ ឬភ្នាក់ងាររបស់រាជរដ្ឋាភិបាលក្នុងរដ្ឋបាលខេត្ត ក្រុងរបស់ខ្លួន និងអំពីកំរិតយល់ដឹង និងឥរិយាបថរបស់មន្ត្រីទាំងនោះ ដើម្បីអនុវត្តនីតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន ក្រោមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងលិខិតបទដ្ឋាននានាសំរាប់អនុវត្តច្បាប់នេះ ។

**ប្រការ ៩.-**

អភិបាលខេត្ត ក្រុងត្រូវពិនិត្យ និងវាយតំលៃអំពីសមត្ថភាព និងលទ្ធភាពរបស់ប្រជារាស្ត្រទូទៅ នៅក្នុងខេត្ត ក្រុងរបស់ខ្លួនដើម្បីធ្វើអន្តរាគមន៍លើការបង្កើនសមត្ថភាពអោយបានសមស្របតាមរយៈការអប់រំ ការបណ្តុះបណ្តាលដោយសៀវភៅ ឯកសារ ផ្ទាំងរូបភាព ការផ្សព្វផ្សាយ ពតិមានផ្សេងៗ ព្រមទាំងការអប់រំ តាមរយៈវិទ្យុ ទូរទស្សន៍ កាសែត និងប្រព័ន្ធផ្សព្វផ្សាយដទៃទៀត ដើម្បីចូលរួមចំណែកក្នុងការគ្រប់គ្រងកិច្ចការឃុំ សង្កាត់របស់ខ្លួន ក្រោមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

**ប្រការ ១០.-**

អភិបាលខេត្ត ក្រុងត្រូវសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីធានាឱ្យមានការបង្កើនសមត្ថភាព ការផ្តល់ធនធានឱ្យបានសមស្របដល់រដ្ឋបាលខេត្ត ក្រុងរបស់ខ្លួន ក្រុមប្រឹក្សាឃុំ សង្កាត់ មន្ត្រីរបស់រាជរដ្ឋាភិបាល និងភ្នាក់ងាររបស់ខ្លួន ព្រមទាំងប្រជារាស្ត្រទូទៅសំរាប់ ដំណើរការ និងចូលរួមក្នុងដំណើរការអភិបាលកិច្ចឃុំ សង្កាត់តាមបែបវិមជ្ឈការ ។

## ជំពូកទី ៤
## អំពីការត្រួតពិនិត្យ និងការធ្វើអន្តរាគមន៍

**ប្រការ ១១.-**

បន្ទាប់ពីកិច្ចប្រជុំដំបូងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ អភិបាលខេត្ត ក្រុងត្រូវពិនិត្យ និងតាមដានអំពីដំណើរការរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីធានាថា :

-ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់បានធ្វើជាអធិបតីក្នុងរាល់កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់

-ក្រុមប្រឹក្សាឃុំ សង្កាត់បានប្រជុំយ៉ាងហោចណាស់មួយដងក្នុងមួយខែ

-បទបញ្ជាផ្ទៃក្នុងដែលក្រុមប្រឹក្សាឃុំ សង្កាត់ បានរៀបចំ និងអនុម័ត ត្រឹមត្រូវតាមគោលការណ៍ណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

-រាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានកោះប្រជុំ បានប្រព្រឹត្តទៅ និងបានកត់ត្រាត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

-រាល់កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានប្រព្រឹត្តឡើងជាសាធារណៈ និងក្នុងលក្ខណៈប្រជាធិបតេយ្យ

-រាល់កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់មានរបៀបរៀបរយល្អ ។

**ប្រការ ១២.-**

អភិបាលខេត្ត ក្រុងត្រូវពិនិត្យ និងវាយតំលៃអំពីការបំពេញការងាររបស់មេឃុំ ចៅសង្កាត់អោយបានត្រឹមត្រូវតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងលិខិតបទដ្ឋានពាក់ព័ន្ធនានាក្នុងការ :

-អនុវត្តន៍សេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

-អនុវត្តន៍តាមគោលនយោបាយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

-ធ្វើសេចក្តីរាយការណ៍ប្រចាំខែជូនក្រុមប្រឹក្សាឃុំ សង្កាត់អំពីការអនុវត្តន៍ការងារ

-ជួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការធ្វើផែនការហិរញ្ញវត្ថុ និងការងារផ្សេងៗទៀតដែលក្រុមប្រឹក្សាឃុំ សង្កាត់ប្រគល់ឱ្យ ។

**ប្រការ ១៣.-**

អភិបាលខេត្ត ក្រុងត្រូវពិនិត្យ និងវាយតំលៃអំពីការបង្កើត និងកិច្ចដំណើរការនៃគណៈកម្មាធិការនានារបស់មេឃុំ ចៅសង្កាត់ ។

ទន្ទឹមនឹងនេះអភិបាលខេត្ត ក្រុងត្រូវពិនិត្យ វាយតំលៃ និងធានាឱ្យការប្រជុំ គណៈកម្មាធិការនីមួយៗបានដំណើរការសមស្របតាមបទបញ្ជាផ្ទៃក្នុងសំរាប់ក្រុមប្រឹក្សាឃុំ សង្កាត់ និងគណៈកម្មាធិការជំនួយការ ។

**ប្រការ ១៤.-**

អភិបាលខេត្ត ក្រុងត្រូវពិនិត្យ វាយតំលៃ និងធានាឱ្យការជ្រើសរើសមេភូមិ និងជំនួយការមេភូមិ ការផ្លាស់ប្តូរមេភូមិ និងជំនួយការមេភូមិ ព្រមទាំងការអនុវត្តន៍ភារកិច្ចរបស់មេភូមិ និងជំនួយការមេភូមិបានសមស្របទៅតាមសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ក្នុងករណីដែលការជ្រើសរើសមេភូមិ និងជំនួយការមេភូមិមិនបានដំណើរការសមស្របទៅតាមបែបបទ និងនីតិវិធីដែលបានចែងក្នុងសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្ត ក្រុងត្រូវធ្វើការណែនាំជាលាយលក្ខណ៍អក្សរដើម្បីឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើការកែតំរូវជាបន្ទាន់ ។

ក្នុងករណីដែលមេភូមិ ឬជំនួយការមេភូមិអនុវត្តមិនបានត្រឹមត្រូវទៅតាមតួនាទី ភារកិច្ច របស់ខ្លួន អភិបាលខេត្ត ក្រុងត្រូវស្នើសុំទៅក្រុមប្រឹក្សាឃុំ សង្កាត់ :

-ឱ្យធ្វើការស៊ើបអង្កេត និងវាយតម្លៃអំពីការខ្វះខាតទាំងនោះ និងវិធានការនានារបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីកែលំអរការខ្វះខាតទាំងនោះ

-ឱ្យធ្វើសេចក្តីរាយការណ៍ជាលាយលក្ខណ៍អក្សរអំពីលទ្ធផលនៃការដោះស្រាយ និងការកែលំអរចំណុចខ្វះខាតរបស់មេភូមិ ឬជំនួយការមេភូមិជូនអភិបាលខេត្ត ក្រុងវិញ ។

**ប្រការ ១៥.-**

អភិបាលខេត្ត-ក្រុង ត្រូវធ្វើអន្តរាគមន៍ក្នុងសមត្ថកិច្ចនៃសិទ្ធិអំណាចជាផ្លូវការរបស់ខ្លួន ហើយត្រូវរាយការណ៍ជាបន្ទាន់ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ពេលដែលសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាមួយទទួលការចោទប្រកាន់ ការចាប់ខ្លួន ឬការឃុំខ្លួនដោយសារការបញ្ចេញមតិ ឬការនិយាយស្តីនៅក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**ប្រការ ១៦.-**

អភិបាលខេត្ត ក្រុងត្រូវត្រួតពិនិត្យ និងធ្វើអន្តរាគមន៍ ចំពោះក្រុមប្រឹក្សាឃុំ សង្កាត់ណាមួយដែលធ្វើសកម្មភាពហួសពីសមត្ថកិច្ចនៃមុខងារ និងអំណាចរបស់ខ្លួន ឬក៏មិនអនុវត្តតាមនីតិវិធី និងភារកិច្ចដែលច្បាប់បានតំរូវ ។

អភិបាលខេត្ត ក្រុងត្រូវធានាកែតំរូវកំហុសឆ្គងទាំងនេះជាបន្ទាន់ ដោយអនុលោមទៅតាមគោលការណ៍ទូទៅដែលចែងក្នុងប្រកាសនេះ ។

**ប្រការ ១៧.-**

អភិបាលខេត្ត ក្រុងត្រូវផ្តួចផ្តើមគំនិត និងអនុវត្តការត្រួតពិនិត្យលើសេចក្តីសំរេច ឬសកម្មភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ឬធ្វើអន្តរាគមន៍លើសេចក្តីសំរេច ឬសកម្មភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងករណី :

-ការត្រួតពិនិត្យ និងការធ្វើអន្តរាគមន៍ ត្រូវបានតំរូវយ៉ាងជាក់លាក់ក្នុងក្របខ័ណ្ឌច្បាប់ ឬលិខិតបទដ្ឋានពាក់ព័ន្ធ

-មានការឆ្លើយតបទៅនឹងសេចក្តីរាយការណ៍ ឬការប្តឹងតវ៉ាដល់អភិបាលខេត្ត ក្រុង ។

**ប្រការ ១៨.-**

ក្នុងករណីដែលច្បាប់ ឬលិខិតបទដ្ឋានតំរូវអោយអភិបាលខេត្ត ក្រុងធ្វើអន្តរាគមន៍ទៅលើសេចក្តីសំរេច ឬសកម្មភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ឬធ្វើអន្តរាគមន៍លើឃុំ សង្កាត់ណាមួយ អភិបាល ខេត្ត ក្រុងត្រូវធានាថា ក្រុមប្រឹក្សាឃុំ សង្កាត់ បាន ឬ នឹងអនុវត្តតាមនីតិវិធីដែលបានតំរូវដោយ :

-ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់

-ព្រះរាជក្រឹត្យ

-អនុក្រឹត្យ ប្រកាស ឬលិខិតបទដ្ឋាននានាដែលបានអនុម័តយល់ព្រម ដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់

-បទបញ្ជាផ្ទៃក្នុង ដីកា ឬ សេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**ប្រការ ១៩.-**

ក្នុងករណីដែលអភិបាលខេត្ត ក្រុងទទួលបានពត៌មានថា ក្រុមប្រឹក្សាឃុំ សង្កាត់មិនអនុវត្តតាមនីតិវិធី និងភារកិច្ចដែលច្បាប់បានតំរូវ អភិបាលខេត្ត ក្រុងត្រូវស្វះស្វែងរកហេតុផលឱ្យបានគ្រប់គ្រាន់ ដើម្បីបញ្ជាក់ថា ពត៌មាននោះត្រឹមត្រូវ ឬមិនត្រឹមត្រូវ ។

អភិបាលខេត្ត ក្រុងអាចតែងតាំងបុគ្គលដែលមានសមត្ថភាពសមស្រប ឬគណៈកម្មការ ឱ្យស៊ើបអង្កេតបញ្ហានេះដើម្បីរាយការណ៍អោយខ្លួនវិញ ។

**ប្រការ ២០.-**

បុគ្គល ឬគណៈកម្មការដែលតែងតាំងដោយអភិបាលខេត្ត ក្រុងមានតួនាទីត្រឹមតែស៊ើបអង្កេត ដើម្បីធ្វើសេចក្ដីរាយការណ៍ជូនអភិបាលខេត្ត ក្រុងរួចហើយអភិបាលខេត្ត ក្រុងត្រូវកំណត់ ថាតើក្រុមប្រឹក្សាឃុំ សង្កាត់នោះធ្វើសកម្មភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវតាមសមត្ថកិច្ចនៃមុខងារ និងអំណាចរបស់ខ្លួន និងនីតិវិធីដែលបានតំរូវដោយ :

-ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

-ព្រះរាជក្រឹត្យ

-អនុក្រឹត្យ ប្រកាស ឬលិខិតបទដ្ឋាននានាដែលបានអនុម័តយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់

-បទបញ្ជាផ្ទៃក្នុង ដីកា ឬសេចក្ដីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**ប្រការ ២១.-**

បុគ្គល ឬគណៈកម្មការដែលបានតែងតាំងដោយអភិបាលខេត្ត ក្រុងអាចត្រួតពិនិត្យឯកសារពាក់ព័ន្ធនីតិវិធី ឬសកម្មភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ និងអាចធ្វើការសាកសួរពត៌មានដែលពាក់ព័ន្ធសមស្រប ព្រមទាំងអាចតំរូវអោយស្មៀនឃុំ សង្កាត់ផ្ដល់ពត៌មានដែលចាំបាច់ ។

**ប្រការ ២២.-**

ប្រសិនបើបុគ្គល ឬគណៈកម្មការនោះរកឃើញថា ក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើសកម្មភាព មិនស្របទៅតាមសមត្ថកិច្ចនៃមុខងារ ឬអំណាចរបស់ខ្លួន ឬមិនបានអនុវត្តតាមនីតិវិធី និងភារកិច្ចដែលច្បាប់បានតំរូវ បុគ្គល ឬគណៈកម្មការនោះត្រូវធ្វើរបាយការណ៍ជូនអភិបាលខេត្ត ក្រុង ។

របាយការណ៍នោះត្រូវដាក់បញ្ចូលនូវ :

-ហេតុផលនៃកំហុសឆ្គង

-វិធីសាស្ត្រកែតំរូវកំហុសឆ្គង

-ប្រភេទនៃសកម្មភាព ឬការធ្វើអន្តរាគមន៍ដទៃទៀតដែលត្រូវការ

-ការគាំទ្រ និងការកសាងសមត្ថភាពណាមួយដែលគួរតែផ្ដល់អោយក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ប្រតិបត្តិអំណាច និងមុខងាររបស់ខ្លួនអោយបានត្រឹមត្រូវ និងដើម្បីជំរុញការអនុវត្តមុខងារ ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អោយកាន់តែប្រសើរឡើង ។

**ប្រការ ២៣.-**

ផ្អែកតាមសេចក្ដីរាយការណ៍របស់បុគ្គល ឬគណៈកម្មការដូចមានចែងក្នុងប្រការ២២ នៃប្រកាសនេះអភិបាលខេត្ត ក្រុងត្រូវ :

-ផ្ដល់យោបល់ជាលាយលក្ខណ៍អក្សរដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីបញ្ជាក់អំពីនីតិវិធី និងតំរូវការផ្អែកច្បាប់អ្វីខ្លះដែលក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុវត្ត

-ណែនាំជាលាយលក្ខណ៍អក្សរដល់ក្រុមប្រឹក្សាឃុំ សង្កាត់ អោយកែតំរូវកំហុសឆ្គងក្នុងកំឡុងពេលសមស្រប និងរាយការណ៍ជូនខ្លួនវិញពេលដែលការកែតំរូវនោះត្រូវបានបញ្ចប់រួចរាល់ ។

**ប្រការ ២៤.-**

នៅពេលដែលក្រុមប្រឹក្សាឃុំ សង្កាត់មិនមានសមត្ថភាពកែតំរូវកំហុសឆ្គងនោះ អភិបាលខេត្ត ក្រុងត្រូវធ្វើកិច្ចការនោះជំនួស ហើយត្រូវចាត់វិធានការចាំបាច់ដើម្បីអភិវឌ្ឍន៍សមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

អភិបាលខេត្ត ក្រុងត្រូវធ្វើសេចក្តីរាយការណ៍ និងផ្តល់អនុសាសន៍ដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអំពីក្រុមប្រឹក្សាឃុំ សង្កាត់ណាមួយ :

-ដែលមិនបានកែតំរូវកំហុសឆ្គងក្នុងរយៈពេល៦ខែបន្ទាប់ពីការធ្វើអន្តរាគមន៍

-ដែលជាទូទៅមិនអនុវត្តតាមនីតិវិធី និងភារកិច្ចដែលច្បាប់បានតំរូវ

-ដែលប្រព្រឹត្តផ្ទុយនឹងរដ្ឋធម្មនុញ្ញ ឬផ្ទុយនឹងគោលនយោបាយរាជរដ្ឋាភិបាលដូចមានចែងក្នុងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋាននានាដែលបានអនុម័តយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ បទ-បញ្ជាផ្ទៃ ក្នុង ដីកា និងសេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**ប្រការ ២៥.-**

អភិបាលខេត្ត ក្រុងមិនអាចធ្វើសេចក្តីសំរេចណាមួយក្នុងនាមក្រុមប្រឹក្សាឃុំ សង្កាត់បានទេ លើកលែងតែក្នុងករណីដែលប្រកាសនេះបានអនុញ្ញាតិអោយ ។

ក្នុងករណីនេះអភិបាលខេត្ត ក្រុងត្រូវធានាថា ក្រុមប្រឹក្សាឃុំ សង្កាត់អនុវត្តតាមនីតិវិធី និងភារកិច្ចដែលច្បាប់បានតំរូវយ៉ាងជាក់លាក់ ។

**ប្រការ ២៦.-**

អភិបាលខេត្ត ក្រុងត្រូវធ្វើការកត់ត្រា ត្រួតពិនិត្យ និងវាយតំលៃចំពោះបញ្ហាទាំងឡាយដូចខាងក្រោម :

-ពេលដែលសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានគំរាមកំហែង ឃាត់ខ្លួន ឬឃុំខ្លួនដោយសារការបញ្ចេញមតិ ឬការនិយាយនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

-ការធ្វើសមាហរណកម្មរបស់កម្មវិធីអភិវឌ្ឍន៍នានាទៅក្នុងប្រព័ន្ធគ្រប់គ្រងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

-ពេលដែល :

-ការបោះឆ្នោត ឃុំ សង្កាត់មិនអាចប្រព្រឹត្តទៅបាន

-វិធានការដាក់វិន័យទៅលើសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

-សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបាត់បង់សមាជិកភាពពីក្រុមប្រឹក្សាឃុំ សង្កាត់

-ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានរំសាយ ហើយការបោះឆ្នោតឡើងវិញអាចប្រព្រឹត្តទៅបាន

-ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានរំសាយហើយការបោះឆ្នោតឡើងវិញមិនអាចប្រព្រឹត្តទៅបាន

-មានបទល្មើសឧក្រិដ្ឋ ឬបទល្មើសមជ្ឈិមកើតមាននៅក្នុងក្រុមប្រឹក្សាឃុំ សង្កាត់

-ការសម្របសម្រួល និងការដោះស្រាយជម្លោះរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងការខ្វែងមតិគ្នារវាងក្រុមប្រឹក្សាឃុំ សង្កាត់ និងអភិបាលខេត្ត ក្រុង

-ការធ្វើប្រតិភូកម្មអំណាចរបស់រដ្ឋទៅអោយឃុំ សង្កាត់

-ទំនាក់ទំនង រវាងក្រុមប្រឹក្សាឃុំ សង្កាត់ និងអង្គការមិនមែនរដ្ឋាភិបាល ជាតិ និងអន្តរជាតិ

-ការចាត់ចែងរួម ឬកិច្ចសហការរវាងក្រុមប្រឹក្សាឃុំ សង្កាត់ និងក្រុមប្រឹក្សាឃុំ សង្កាត់

-សំណើបង្កើត លុបចោល កែប្រែព្រំប្រទល់ និងប្តូរឈ្មោះរបស់ឃុំ សង្កាត់

-បញ្ហាទាំងឡាយដែលតំរូវអោយអភិបាលខេត្ត ក្រុងអនុវត្តក្នុងការអនុម័ត ការត្រួតពិនិត្យ ការកសាងសមត្ថភាព ឬការធ្វើអន្តរាគមន៍ ។

**ប្រការ ២៧.-**

អភិបាលខេត្ត ក្រុងត្រូវត្រួតពិនិត្យ និងវាយតំលៃជាប្រចាំអំពីការវិវត្តន៍ប្រែប្រួល និងសមត្ថភាពរបស់ឃុំ សង្កាត់ ។

អភិបាលខេត្ត ក្រុងត្រូវធ្វើសេចក្តីរាយការណ៍ និងផ្តល់អនុសាសន៍រៀងរាល់ ៣ខែម្តង អំពីការវិវត្តន៍ប្រែប្រួល និងសមត្ថភាពរបស់ឃុំ សង្កាត់ ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

**ប្រការ ២៨.-**

គោលការណ៍ជាទូទៅដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យ និងការធ្វើអន្តរាគមន៍ ត្រូវដាក់អោយអនុវត្តផងដែរចំពោះបញ្ហាមួយចំនួនដែលទាក់ទងនឹងសេចក្តីសំរេច ឬសកម្មភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

បញ្ហាទាំងនោះរួមមាន :

-កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់

-កិច្ចប្រជុំគណៈកម្មាធិការ

-ភារកិច្ចរបស់មេឃុំ ចៅសង្កាត់

-ការជ្រើសរើស និងរបៀបរបបធ្វើការងាររបស់មេភូមិ

-ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

-ហិរញ្ញវត្ថុ និងថវិកាឃុំ សង្កាត់

-ការអនុវត្តន៍ការងាររបស់ឃុំ សង្កាត់

-មោឃភាពសេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងដីកាឃុំ សង្កាត់ ។

**ប្រការ ២៩.-**

អភិបាលខេត្ត ក្រុងត្រូវសម្រេចយល់ព្រម ឬមិនយល់ព្រមលើពាក្យស្នើរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីសុំកាត់មួយផ្នែក ឬទាំងអស់នៃប្រាក់ឧបត្ថម្ភរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាម្នាក់ ដែលទទួលវិន័យស្តីបន្ទោសក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់នោះរួចហើយ ប៉ុន្តែសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបនោះ នៅតែបន្តប្រព្រឹត្តកំហុសតទៅទៀត ។

ក្នុងករណីដែលសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាម្នាក់មិនអនុវត្តតាមបទប្បញ្ញត្តិណាមួយ ឬច្រើននៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឬប្រព្រឹត្តផ្ទុយពីបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបនោះនឹងទទួលវិន័យជាបឋម ដោយការស្តីបន្ទោសក្នុងអង្គប្រជុំក្រុមប្រឹក្សា ឃុំ សង្កាត់របស់ខ្លួន ដោយមានកំណត់

ហេតុច្បាស់លាស់ ។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបញ្ជូនកំណត់ហេតុនេះជាបន្ទាន់ ទៅអភិបាលខេត្ត ក្រុងដើម្បីធ្វើការស៊ើបអង្កេត និងវាយតម្លៃ ។

បន្ទាប់ពីបានទទួលវិន័យខាងលើនេះហើយ ប៉ុន្តែសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបនោះនៅតែ បន្តប្រព្រឹត្តកំហុស ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវស្នើទៅអភិបាលខេត្ត ក្រុងដើម្បីស្នើសុំកាត់មួយផ្នែក ឬទាំងអស់នូវប្រាក់ឧបត្ថម្ភរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបនោះ ។

ក្នុងករណីអនុវត្តរូបភាពវិន័យទាំងពីរខាងលើរួចហើយ ប៉ុន្តែសមាជិកក្រុមប្រឹក្សារូបនោះនៅតែមិនរាងចាល ក្រុមប្រឹក្សាឃុំ សង្កាត់អាចបញ្ឈប់ជននោះពីមុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដោយការបោះឆ្នោតតាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល ។

អភិបាលខេត្ត ក្រុង ត្រូវធ្វើការស៊ើបអង្កេតដើម្បីវាយតម្លៃថា ក្រុមប្រឹក្សាឃុំ សង្កាត់បានអនុវត្តត្រឹមត្រូវតាមនីតិវិធីនេះ ។

**ប្រការ ៣០.-**

អភិបាលខេត្ត ក្រុងត្រូវសំរេចអំពីការបាត់បង់សមាជិកភាពរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមូលហេតុណាមួយដូចខាងក្រោម :

-សាមីខ្លួនទទួលមរណភាព

-សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈខាងផ្លូវចិត្ត ឬផ្លូវកាយដោយមានការបញ្ជាក់ពីក្រសួង ឬស្ថាប័នមានសមត្ថកិច្ច

-សាមីខ្លួនសុំលាលែងជាលាយលក្ខណ៍អក្សរពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

-សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ

-សាមីខ្លួនត្រូវបានបណ្តេញចេញដោយប្រព្រឹត្តផ្ទុយនឹងបទបញ្ជាផ្ទៃក្នុង តាមលក្ខខណ្ឌដែលបានកំណត់ក្នុងច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ

-សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ។

**ប្រការ ៣១.-**

ក្នុងករណីដែលមានភស្តុតាងជាក់លាក់ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាម្នាក់បាត់បង់សមាជិកភាពរបស់ខ្លួន ដោយហេតុផលណាមួយក្នុងចំណោមហេតុផលដូចមានចែងក្នុងប្រការ ៣០ នៃប្រកាសនេះ អភិបាលខេត្ត ក្រុងត្រូវធ្វើសេចក្តីរាយការណ៍ជាបន្ទាន់ជូនដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីស្នើដាក់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ថ្មីជំនួសស្របតាមច្បាប់ និងនីតិវិធីដែលបានកំណត់ ។

**ប្រការ ៣២.-**

អភិបាលខេត្ត ក្រុងត្រូវបញ្ជូនទៅអាជ្ញាធរតុលាការ ឬនគរបាលជាតិ និងក្រសួងមហាផ្ទៃនូវសេចក្តីរាយការណ៍ ឬការប្តឹងតវ៉ាណាមួយដែលបញ្ជាក់ថា សេចក្តីសំរេច ឬសកម្មភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ បុគ្គលិកនៃក្រុមប្រឹក្សាឃុំ សង្កាត់ បានប្រព្រឹត្តនូវបទឧក្រិដ្ឋ ឬបទមជ្ឈិម ។

អភិបាលខេត្ត ក្រុងត្រូវតាមដានអោយបានដិតដល់នូវបញ្ហាខាងលើនេះ និងរាយការណ៍អំពីលទ្ធផលនៃដំណោះស្រាយជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី ៥
## អំពីការគ្រប់គ្រងឃុំ សង្កាត់ដែលទើបបង្កើតថ្មី
## និងឃុំ សង្កាត់ដែលក្រុមប្រឹក្សាត្រូវរំសាយ

### ប្រការ ៣៣._

អភិបាលខេត្ត ក្រុងត្រូវធានាចាត់ចែងកិច្ចការជាបណ្តោះអាសន្ន ចំពោះឃុំ សង្កាត់ដែលទើបបង្កើតថ្មី និងឃុំ សង្កាត់ដែលក្រុមប្រឹក្សាត្រូវរំសាយ ។

### ប្រការ ៣៤._

អភិបាលខេត្ត ក្រុងត្រូវតែងតាំងបុគ្គល ឬគណៈកម្មការជាបន្ទាន់ ដើម្បីចាត់ចែងកិច្ចការឃុំ សង្កាត់ដូចមានចែងក្នុងប្រការ ៣៣ នៃប្រកាសនេះ ។

អភិបាលខេត្ត ក្រុងត្រូវធ្វើការពិគ្រោះយោបល់ជាមួយនាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ ដើម្បីលើកយោបល់ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃពិនិត្យ និងសំរេចអំពីការងាររបស់បុគ្គល ឬគណៈកម្មការនោះ ។

ការកំណត់ការងារនេះ :

-ត្រូវផ្អែកលើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងលិខិតបទដ្ឋានពាក់ព័ន្ធនានា

-ត្រូវគ្រប់គ្រងកិច្ចការប្រចាំថ្ងៃ របស់ឃុំ សង្កាត់តែប៉ុណ្ណោះ

-មិនអាចអនុម័តលើផែនការអភិវឌ្ឍន៍ និងថវិកាឃុំ សង្កាត់ ឬចុះកិច្ចសន្យា ឬសកម្មភាពណាមួយដែលរំលោភលើសិទ្ធិអំណាចរបស់ឃុំ សង្កាត់ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីអភិបាលខេត្ត ក្រុងបានឡើយ ។

## ជំពូកទី៦
## អំពីការរំសាយក្រុមប្រឹក្សាឃុំ សង្កាត់ និងការគ្រប់គ្រងឃុំ សង្កាត់ជាបណ្តោះអាសន្ន

### ប្រការ ៣៥._

អភិបាលខេត្ត ក្រុងត្រូវរាយការណ៍ និងផ្តល់អនុសាសន៍ដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មុនពេលដែលរដ្ឋមន្ត្រីក្រសួងមហាផ្ទៃធ្វើការរំសាយក្រុមប្រឹក្សាឃុំ សង្កាត់ដោយយោងតាមមាត្រា ៥៧ ឬមាត្រា៥៨ នៃច្បាប់ស្តីពីការគ្រប់គ្រង រដ្ឋបាលឃុំ សង្កាត់ ។

ករណីដែលរដ្ឋមន្ត្រីក្រសួងមហាផ្ទៃរំសាយក្រុមប្រឹក្សាឃុំ សង្កាត់យោងតាមមាត្រា ៥៧ ឬ៥៨នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ហើយអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ មានរយៈពេល មិនលើសពី ១៨០ថ្ងៃ គិត

ចាប់ពីថ្ងៃរំសាយក្រុមប្រឹក្សាឃុំ សង្កាត់ អភិបាលខេត្ត ក្រុង ត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ហើយការបោះឆ្នោតឡើងវិញនៅឃុំ សង្កាត់នោះមិនត្រូវរៀបចំឡើយ ។

ករណីដែលរដ្ឋមន្ត្រីក្រសួងមហាផ្ទៃរំសាយក្រុមប្រឹក្សាឃុំ សង្កាត់ដោយយោងតាមមាត្រា ៥៧ ឬមាត្រា ៥៨នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ហើយអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ លើសពី ១៨០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការរំសាយក្រុមប្រឹក្សាឃុំ សង្កាត់ អភិបាលខេត្ត ក្រុងត្រូវស្នើសុំទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អោយកំណត់កាលបរិច្ឆេទ នៃការបោះឆ្នោតឡើងវិញ ។

**ប្រការ ៣៦.-**

ក្នុងករណីដែលអាណត្តិនៅសល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់មានរយៈពេលលើសពី ១៨០ថ្ងៃ អភិបាលខេត្ត ក្រុងត្រូវតែងតាំងបុគ្គល ឬគណៈកម្មការជាបន្ទាន់ដើម្បីចាត់ចែងកិច្ចការជាបណ្តោះអាសន្ននៅឃុំ សង្កាត់ដែលបានរំសាយក្រុមប្រឹក្សារហូតដល់ការបោះឆ្នោតឡើងវិញអាចប្រព្រឹត្តទៅបាន ។

អភិបាលខេត្ត ក្រុងត្រូវកំណត់ការងាររបស់បុគ្គល ឬគណៈកម្មការនោះ តាមលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ ៣៤ នៃប្រកាសនេះ ។

**ប្រការ ៣៧.-**

ក្នុងករណីដែលអាណត្តិនៅសល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ មានរយៈពេលមិនលើសពី ១៨០ថ្ងៃ អភិបាលខេត្ត ក្រុង ត្រូវតែងតាំងបុគ្គល ឬគណៈកម្មការជាបន្ទាន់ដើម្បីចាត់ចែងកិច្ចការឃុំ សង្កាត់ជាបណ្តោះអាសន្នរហូតដល់ក្រុមប្រឹក្សាឃុំ សង្កាត់ថ្មី ត្រូវបានបោះឆ្នោតជ្រើសរើសឡើងនាអាណត្តិបន្ទាប់ ។

អភិបាលខេត្ត ក្រុងត្រូវកំណត់ការងាររបស់បុគ្គល ឬគណៈកម្មការនោះតាមលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ ៣៤ នៃប្រកាសនេះ ។

## ជំពូកទី ៧

## អំពីដំណោះស្រាយជំលោះ

**ប្រការ ៣៨.-**

អភិបាលខេត្ត ក្រុងត្រូវសម្របសម្រួលរវាងឃុំ សង្កាត់ពីរ ឬច្រើន អំពីបញ្ហាណាមួយដែលមានភាពប្រទាញប្រទង់ ឬមានជម្លោះជាមួយគ្នាហើយដែលឃុំ សង្កាត់ទាំងនោះមិនអាចដោះស្រាយបាន ។

ការដោះស្រាយរបស់អភិបាលខេត្ត ក្រុងត្រូវឈរលើមូលដ្ឋាននៃការគោរពនូវផលប្រយោជន៍ទាំងសងខាង ។

អភិបាលខេត្ត ក្រុងត្រូវសហការ និងពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន ឬភ្នាក់ងារពាក់ព័ន្ធដើម្បីដោះស្រាយបញ្ហាដែលមានភាពប្រទាញប្រទង់ ឬមានជម្លោះពាក់ព័ន្ធនឹងការធ្វើប្រតិភូកម្មអំណាចរបស់រដ្ឋចំពោះឃុំ សង្កាត់ ឬសេចក្តីសំរេច ឬសកម្មភាពរបស់ក្រសួង ស្ថាប័ន ឬភ្នាក់ងារទាំងនោះ ។

**ប្រការ ៣៩.-**

ក្នុងករណីដែលអភិបាលខេត្ត ក្រុងបានដោះស្រាយបញ្ហាណាមួយដែលមានភាពប្រទាញប្រទង់ ឬមានជម្លោះជាមួយគ្នា លើមូលដ្ឋាននៃការធានាបាននូវប្រយោជន៍សំរាប់គ្រប់ភាគី និងអ្នកពាក់ព័ន្ធទាំងអស់ហើយអភិបាលខេត្ត ក្រុងត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**ប្រការ ៤០.-**

ក្នុងករណីដែលបញ្ហាណាមួយមានភាពប្រទាញប្រទង់ ឬមានជម្លោះជាមួយគ្នា ក្រោយពីបានដោះស្រាយហើយ តែគូភាគី និងអ្នកដែលពាក់ព័ន្ធនៅតែមិនស្រុះស្រួលជាមួយគ្នា អភិបាលខេត្ត ក្រុងត្រូវធ្វើសេចក្តីរាយការណ៍អំពីបញ្ហាទាំងនោះ និងផ្តល់អនុសាសន៍ដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃដើម្បីបន្តដោះស្រាយ ។

## ជំពូកទី ៨
## អំពីការធ្វើអន្តរាគមន៍
## ចំពោះការធ្វើវិសហមជ្ឈការអំណាចរបស់រដ្ឋ

**ប្រការ ៤១.-**

អភិបាលខេត្ត ក្រុងត្រូវធ្វើការពិនិត្យបញ្ជាក់គ្រប់កិច្ចព្រមព្រៀង ឬការងារដែលស្នើឡើងដោយក្រសួងស្ថាប័ន ឬភ្នាក់ងាររបស់រាជរដ្ឋាភិបាលក្នុងការធ្វើប្រតិភូកម្មអំណាច ឬការទទួលខុសត្រូវឱ្យដល់ឃុំ សង្កាត់បានអនុវត្តត្រឹមត្រូវតាមលក្ខខណ្ឌដែលកំណត់ដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

អភិបាលខេត្ត ក្រុងត្រូវបដិសេធគ្រប់កិច្ចព្រមព្រៀង ឬការងារដែលបានស្នើឡើងមិនស្របនឹងលក្ខខណ្ឌដែលកំណត់ដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ហើយត្រូវផ្តល់ពត៌មានដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

បន្ទាប់ពីបានពិនិត្យនិងបញ្ជាក់ចំពោះកិច្ចព្រមព្រៀងការងារដែលបានស្នើឡើងមានលក្ខណៈត្រឹមត្រូវរួចហើយអភិ-បាលខេត្ត ក្រុងត្រូវផ្តល់ពត៌មានដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**ប្រការ ៤២.-**

ក្នុងការធ្វើប្រតិភូកម្មអំណាចរដ្ឋដល់ក្រុមប្រឹក្សាឃុំ សង្កាត់ អភិបាលខេត្ត ក្រុងត្រូវ :

-ត្រួតពិនិត្យការអនុវត្តន៍ កិច្ចព្រមព្រៀងការងារ ដែលក្រសួងស្ថាប័ន ឬភ្នាក់ងាររបស់រាជរដ្ឋាភិបាលបានយល់ព្រមប្រគល់ឱ្យឃុំ សង្កាត់ និងធានាឱ្យមានការប្រគល់នូវធនធាន សមត្ថភាព និងកំរៃបានសមស្រប

-ធ្វើសេចក្តីរាយការណ៍អំពីកង្វះខាតរបស់ក្រសួង ស្ថាប័ន ឬភ្នាក់ងាររបស់រាជរដ្ឋាភិបាលដែលបានធ្វើប្រតិភូកម្មអំណាចឱ្យដល់ឃុំ សង្កាត់ជូនគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ និងក្រសួងមហាផ្ទៃ ព្រមទាំងក្រសួងស្ថាប័ន ឬភ្នាក់ងាររបស់រាជរដ្ឋាភិបាល

-ផ្តល់អនុសាសន៍ដល់ក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័ន ឬភ្នាក់ងាររបស់រាជរដ្ឋាភិបាល អំពីការផ្លាស់ប្តូរ ឬការកែសម្រួលលើកិច្ចព្រមព្រៀងនានា ។

**ប្រការ ៤៣.-**

ក្នុងករណីដែលមានស្រុក ខណ្ឌ ឃុំ សង្កាត់ ឬភូមិចូលរួមក្នុងកម្មវិធី ឬគំរោងនានារបស់រដ្ឋ ហើយដែលមានការសំរេចពីគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ដើម្បីនឹងធ្វើសមាហរណកម្មកម្មវិធី ឬគំរោងទាំងនោះទៅក្នុងប្រព័ន្ធគ្រប់គ្រងថ្មីនៃឃុំ សង្កាត់ អភិបាលខេត្ត ក្រុង ត្រូវត្រួតពិនិត្យ និងធានាឱ្យមានការផ្ទេរ និងការអនុវត្តន៍អោយបានត្រឹមត្រូវនូវការទទួលខុសត្រូវ មុខងារ និងទ្រព្យសម្បត្តិ ពីកម្មវិធី ឬគំរោងទាំងនោះរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**ប្រការ ៤៤.-**

អភិបាលខេត្ត ក្រុងត្រូវធ្វើការពិនិត្យ និងវាយតម្លៃមុននឹងធ្វើសេចក្តីរាយការណ៍ និងផ្តល់អនុសាសន៍ដល់ គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ និងក្រសួងមហាផ្ទៃ នូវ :

-កិច្ចព្រមព្រៀង ឬកម្មវិធី ឬគំរោងនានា ឬការចាត់ចែងណាមួយដោយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ

-ការចាត់ចែងណាមួយមុនការបោះឆ្នោតលើកទី១ នេះហើយដែលមិនទាន់បានពិភាក្សាគ្នា ក្នុងការធ្វើសមាហរណកម្មទៅក្នុងប្រព័ន្ធគ្រប់គ្រងថ្មី ឬការសម្របសម្រួលជាមួយប្រព័ន្ធគ្រប់គ្រងថ្មីនៃឃុំ សង្កាត់ដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

## ជំពូកទី ៩
## អំពីការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់
## និងការប្តូរឈ្មោះរបស់ឃុំ សង្កាត់

**ប្រការ ៤៥.-**

អភិបាលខេត្ត ក្រុងត្រូវធ្វើសេចក្តីរាយការណ៍ និងផ្តល់អនុសាសន៍ជូនគណៈកម្មាធិការជាតិ គាំទ្រឃុំ សង្កាត់ និងក្រសួងមហាផ្ទៃនូវសំណើ ឬសំណូមពរនានាអំពីការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់ ឬការប្តូរឈ្មោះរបស់ឃុំ សង្កាត់ ។

**ប្រការ ៤៦.-**

អភិបាលខេត្ត ក្រុងត្រូវធ្វើសេចក្តីរាយការណ៍ និងផ្តល់អនុសាសន៍ ជូនគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ និងក្រសួងមហាផ្ទៃ អំពីផលលំបាកនានាដែលបណ្តាលមកពីការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់ ឬការប្តូរឈ្មោះរបស់ឃុំ សង្កាត់ ដែលបានស្នើឡើងដោយក្រុមប្រឹក្សាឃុំ សង្កាត់រួម ឬដោយអភិបាលស្រុក ខណ្ឌ រួមមានការចាត់ចែងកិច្ចសន្យាសំខាន់ៗ រចនាសម្ព័ន្ធ និងប្រព័ន្ធ អំណាច និងមុខងារ ការចាត់ចែង ហិរញ្ញវត្ថុ និងថវិកា ព្រមទាំងបុគ្គលិក ។

## ជំពូកទី ១០
## អំពីមោឃភាពនៃដីកា ឬសេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

**ប្រការ ៤៧.-**

ក្នុងករណីពិនិត្យឃើញថា សេចក្តីសំរេច ឬដីកាណាមួយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ផ្ទុយនឹងរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ឬលិខិតបទដ្ឋាននានា អភិបាលខេត្ត ក្រុងត្រូវធ្វើសំណើជាបន្ទាន់មករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីប្រកាសមោឃៈភាពជាលាយលក្ខណ៍អក្សរដល់ក្រុមប្រឹក្សាឃុំ សង្កាត់សាមី និងផ្សព្វផ្សាយជាសាធារណៈ ។

## ជំពូកទី ១១
## អំពីអន្តរប្បញ្ញត្តិ

**ប្រការ ៤៨.-**

អភិបាលខេត្ត ក្រុងត្រូវធ្វើសេចក្តីរាយការណ៍ដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអំពីឃុំ សង្កាត់ដែលពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីអនុវត្តនយោបាយវិមជ្ឈការ ដើម្បីធ្វើការកំណត់អំពីរបបគ្រប់គ្រងរដ្ឋបាលអន្តរកាលចំពោះឃុំ សង្កាត់នោះ បន្ទាប់ពីបានសំរេចយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

ការកំណត់របបគ្រប់គ្រងរដ្ឋបាលអន្តរកាលនេះ ត្រូវអនុវត្តដូចមាត្រា ៣៤ នៃប្រកាសនេះ ។

## ជំពូកទី ១២
## អំពីអវសានប្បញ្ញត្តិ

**ប្រការ ៤៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥០.-**

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០០២

**សហរដ្ឋមន្ត្រី**

**ហត្ថលេខា** **ហត្ថលេខា**

**ស ខេង** **យូ ហុកគ្រី**

**<u>ចម្លងជូន</u>**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-សមាជិក "គ.ឃ.ស"

-ក្រសួងស្ថាប័នពាក់ព័ន្ធ

-សាលាខេត្ត ក្រុង

-ឯកសារ -កាលប្បវត្តិ